**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាកលវិទ្យាល័យស្វាយរៀង**

# ផែនការយុទ្ធសាស្ត្រដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
# នៃសាកលវិទ្យាល័យស្វាយរៀង

សាកលវិទ្យាល័យស្វាយរៀងត្រូវបានកសាងឡើងក្នុងឆ្នាំ២០០៤ស្របពេលដែលការអភិវឌ្ឍរបស់ប្រទេសកម្ពុជាកំពុងមានសន្ទុះយ៉ាងខ្លាំងក្រោមការដឹកនាំដ៏ឈ្លាសវៃប្រកបដោយគតិបណ្ឌិតរបស់**សម្តេចអគ្គ មហាសេនាបតីតេជោ ហ៊ុនសែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ជាពិសេសលើទឹកដីខេត្តស្វាយរៀងដែលបានបង្កើតឡើងនូវតំបន់សេដ្ឋកិច្ចពិសេសនៅទីប្រជុំជនក្រុងបាវិត ។ គ្រឹះស្ថាននេះបានបង្កើតឡើងក្រោមគំនិតផ្តួចផ្តើម និង ដឹកនាំកសាងដោយ **សពឯកឧត្តម នាយឧត្តមសេនីយ៍ ហុក ឡុងឌី អតីតអគ្គស្នងការនគបាលជាតិ** និង **ឯកឧត្តម ហ៊ុន ណេង អតីតអភិបាលខេត្តស្វាយរៀង** ក្នុងគោលបំណងបណ្តុះបណ្តាលធនធានមនុស្សសម្រាប់ការអភិវឌ្ឍន៍មាតុភូមិកម្ពុជាឲ្យកាន់តែរីកចម្រើន។

សាកលវិទ្យាល័យស្វាយរៀង គឺជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈមួយចំណុះឲ្យក្រសួងអប់រំ យុវជន និងកីឡាត្រូវបានបង្កើតឡើងដោយអនុក្រឹតលេខៈ៧៣ អនក្រ.ប្រកចុះថ្ងៃទី២៧ ខែ ឧសភា ឆ្នាំ២០០៥ និងមានទីតាំងស្ថិតនៅភូមិ ចំបក់ សង្កាត់ ចេក ក្រុង ស្វាយរៀង ខេត្ត ស្វាយរៀង លើផ្ទៃដីប្រមាណ៦ហិកតា និងសម្ពោធដាក់ឲ្យដំណើរការជាផ្លូវការក្រោមអធិបតីដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** និង **លោកជំទាវ** នៅថ្ងៃទី២៥ ខែ មករា ឆ្នាំ២០០៦។

ការបណ្តុះបណ្តាលនៅសាកលវិទ្យាល័យស្វាយរៀងមានបីកម្រិត គឺថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ថ្នាក់បរិញ្ញាបត្រនិងថ្នាក់បរិញ្ញាបត្ររង។ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៃសាកលវិទ្យាល័យស្វាយរៀងគឺជាស្ពានចម្លងមួយដែលប្រើសម្រាប់ភ្ជាប់ពីចំណេះដឹងទូទៅទៅកាន់ជំនាញប្រកបដោយគុណភាពនិងប្រសិទ្ធភាព ។ ដូច្នេះដើម្បីឲ្យនិស្សិត និងសាធារណៈជនគ្រប់មជ្ឈដ្ឋានមានទំនុកចិត្តទៅលើសាកលវិទ្យាល័យស្វាយរៀងជាពិសេសនៅថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននោះ សាកលវិទ្យាល័យស្វាយរៀងបានបង្កើតផែនការយុទ្ធសាស្ត្ររបស់ខ្លួនសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដើម្បីពង្រឹងគុណភាពបណ្តុះបណ្តាលរបស់ខ្លួនដែលមានៈ

**ចក្ខុវិស័យ**

ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន នៃសាកលវិទ្យាល័យស្វាយរៀងជាមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្រិតមូលដ្ឋានមួយដែលតម្រង់ទិសទៅកាន់មុខជំនាញប្រកបដោយសមត្ថភាព គុណភាព សីលធម៌ និងភាពប៉ិនប្រសប់។

**បេសកកម្ម**

ដើម្បីសម្រេចបាននូវចក្ខុវិស័យខាងលើ ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៃសាកលវិទ្យាល័យស្វាយរៀងត្រូវមានបេសកកម្មដូចខាងក្រោម:

- បង្កើនសមត្ថភាពជំនាញដល់និស្សិតតាមរយៈ ការបណ្តុះគំនិតការសិក្សាស្រាវជ្រាវ និង ប្រើប្រាស់បណ្ណាល័យក្នុងការបង្រៀន ការរៀន ដើម្បីចូលរួមអភិវឌ្ឍន៍សង្គមប្រកបដោយនិរន្តភាព
- ផ្តល់នូវកម្មវិធីសិក្សាថ្មីៗដែលសមស្របទៅនឹងការអភិវឌ្ឍន៍នៅក្នុងតំបន់
- ការអនុវត្តន៍ជាមូលដ្ឋាន

**គោលដៅ**

ដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាននៃសាកលវិទ្យាល័យស្វាយរៀងមានគោលដៅដូចតទៅ:

- ផ្តល់ចំណេះដឹងមូលដ្ឋានទូទៅដែលជាគ្រឹះសម្រាប់បន្តការសិក្សាកម្រិតឧត្តមដោយជោគជ័យ
- ចូលរួមលើកស្ទួយគុណភាពអប់រំកម្រិតឧត្តមសិក្សានៅកម្ពុជាឲ្យមានកម្រិតជាសាកល

**វត្ថុបំណង**

- និស្សិតនឹងទទួលបាននូវចំណេះដឹងជាមូលដ្ឋានតាមរយៈការបណ្តុះបណ្តាលនៃមុខវិជ្ជាក្នុងវិស័យទាំងបួន
- និស្សិតនឹងទទួលបាននូវសមត្ថភាពក្នុងការសិក្សាស្រាវជ្រាវ និង អនុវត្តពីជំនាញវិជ្ជាជីវៈរបស់ខ្លួន
- និស្សិតនឹងទទួលបាននូវសីលសម្បត្តិព្រមទាំងមានទំនួលខុសត្រូវខ្ពស់

**ផែនការយុទ្ធសាស្ត្ររយៈពេល៣ឆ្នាំ ២០០៩-២០១២**

ដើម្បីសម្រេចឲ្យបាននូវចក្ខុវិស័យ និង គោលដៅខាងលើដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានបានដាក់ចេញនូវផែនការអនុវត្តរយៈពេលបីឆ្នាំដូចខាងក្រោម:

**១-ធនធានមនុស្ស**

- បន្តពង្រឹងនិង បង្កើនសមត្ថភាពសាស្ត្រាចារ្យ និង បុគ្គលិកបំរើការក្នុងដេប៉ាតឺម៉ង់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន
- បន្តស្នើសុំសាស្ត្រាចារ្យក្របខណ្ឌរដ្ឋដែលមានកម្រិតជំនាញនិងចំណេះដឹងទូលំទូលាយនឹងសមស្របទៅនឹងលក្ខខណ្ឌរបស់គណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា។

## ២-កម្មវិធីសិក្សា

- បន្តអភិវឌ្ឍកម្មវិធី និង ផ្តល់វិធីសិក្សាថ្មីៗសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានដែលឆ្លើយតបទៅនឹងតម្រូវការរបស់និស្សិតក្នុងការបន្តការសិក្សាថ្នាក់បរិញ្ញាបត្រ។

## ៣-សម្ភារៈឧបទ្ទេស

- បង្កើននូវសម្ភារៈឧបទ្ទេសបន្ថែម ដូចជា LCD,ម៉ាញ៉េ ,ទូរទស្សន៍...និងសម្ភារៈផ្សេងៗដែលបំរើឲ្យបរិយាកាសនៃការសិក្សាឲ្យកាន់តែប្រសើរ

## ៤-សម្ភារៈរូបវន្ត

- សាងសង់មួយអាគារសិក្សាថ្មីបន្ថែមដើម្បីបំពេញទៅតាមតម្រូវការនៃការកើនឡើងនៃចំនួននិស្សិត
- បង្កើនបន្ទប់អនុវត្តន៍កុំព្យូទ័រសម្រាប់ឲ្យនិស្សិតបង្កើនជំនាញ និង ចំណេះដឹងផ្នែកព័ត៏មានវិទ្យា

## ៥-សេវា

- ធ្វើបទបង្ហាញស្តីពីការសិក្សានៅសាកលវិទ្យាល័យស្វាយរៀងនៅតាមវិទ្យាល័យគោលដៅមួយចំនួន
- បន្ថែមនិងកែលំអរសម្ភារៈនៅក្នុងបន្ទប់អនុវត្តន៍
- បង្កើនល្បឿននៃប្រព័ន្ធអ៊ីនធឺណែតឲ្យកាន់តែលឿន
- បង្កើនចំនួនសៀវភៅ និងឯកសារសម្រាប់ថ្នាក់ឆ្នាំសិក្សាមូលដ្ឋានឲ្យបានកាន់តែសម្បូរបែប។
- បង្កើនសម្ភារៈសម្រាប់បន្ទប់ពិសោធន៍គីមី-ជីវវិទ្យា
- កសាងអាហារដ្ឋាន និងបណ្ណាគារនៅក្នុងសាកលវិទ្យាល័យស្វាយរៀង